ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសរបស់អ្នកនាំពាក្យ
# នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# នៃព្រះរាជាណាចក្រកម្ពុជា

1. អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានការខកចិត្តយ៉ាងខ្លាំងចំពោះសេចក្តីប្រកាសនៅថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ២០១៧ របស់ក្រសួងការបរទេសអាមេរិក ស្តីពីការដាក់កម្រិតទិដ្ឋាការបន្ថែមទៀតដែលជាការឆ្លើយតបទៅនឹងវិធានការស្របច្បាប់អនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ចក្រោមសិទ្ធិអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា។

2. កម្ពុជាបានធ្វើការកត់សម្គាល់ដោយមានការសោកស្តាយយ៉ាងខ្លាំង ចំពោះការសម្រេចចិត្តចុងក្រោយរបស់ក្រសួងការបរទេសអាមេរិកដែលពុំបានពិចារណាលើអង្គហេតុ និងអង្គច្បាប់ជុំវិញការវិវឌ្ឍនយោបាយថ្មីៗនៅកម្ពុជា ហើយការសម្រេចចិត្តនេះគឺធ្វើឡើងដោយសារហេតុផលនយោបាយដោយមានការគិតទុកជាមុន និងមានស្តង់ដារពីរ។ ការសម្រេចចិត្តនេះផ្ទុយពីស្មារតីនៃការបន្តកិច្ចខិតខំប្រឹងប្រែងធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងកម្ពុជានិងសហរដ្ឋអាមេរិក បន្ទាប់ពីរដ្ឋាភិបាលអាមេរិកដាក់កម្រិតទិដ្ឋាការដ៏អយុត្តិធម៌ កាលពីខែកញ្ញា ឆ្នាំ ២០១៧ ដោយកម្ពុជាគ្រាន់តែស្នើឲ្យយកចិត្តទុកដាក់ចំពោះទិដ្ឋភាពមនុស្សធម៌ និងមេត្តាធម៌ក្នុងកិច្ចសហប្រតិបត្តិការនៃកម្មវិធីមាតុភូមិនិវត្តន៍។

3. ជាការដែលមិនអាចប្រកែកបានដែលថា ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សត្រូវតែដើរទន្ទឹមនឹងការពង្រឹងនីតិរដ្ឋ។ ដូច្នេះ វិធានការច្បាប់ប្រឆាំងនឹងបុគ្គល អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយមួយចំនួនតូចដែលបានបំពានច្បាប់ មិនគួរត្រូវបានចាត់ទុកថាជាការប៉ុនប៉ងធ្វើឲ្យលំហលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាចុះខ្សោយនោះទេ។ វិធានការទាំងនេះត្រូវបានដាក់ចេញក្នុងគោលបំណងការពារអធិបតេយ្យភាព សន្តិភាព ស្ថិរភាព និងសន្តិសុខជាតិ។ អ្នកនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនផ្សេងទៀត រួមទាំងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលមិនបានបំពានច្បាប់ នៅតែបន្តអនុវត្តការងាររបស់ពួកគេដោយសេរីនៅទូទាំងប្រទេស។ ក្នុងន័យនេះ រាល់ការគាំទ្រណាមួយដល់បុគ្គល និងអង្គភាពដែលបំពានច្បាប់គឺមានន័យស្មើនឹងការសម្លាប់ដំណើរការប្រជាធិបតេយ្យប្រកបដោយសន្តិភាពក្រោមនីតិរដ្ឋនៅកម្ពុជា។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

4. ការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងគឺជាបញ្ហារសើបសម្រាប់ប្រទេសកម្ពុជាក៏ដូចជារដ្ឋអធិបតេយ្យផ្សេងទៀតដែរ។ ដូចក្នុងករណីលោក Paul Manafort និងលោក Rick Gates បានបង្ហាញយ៉ាងច្បាស់អំពីភាពរសើបរបស់អាមេរិកចំពោះការជ្រៀតជ្រែកពីបរទេស។ ប្រវត្តិសាស្ត្របានបញ្ជាក់យ៉ាងច្បាស់ថា ការជ្រៀតជ្រែកពីបរទេសតែងតែបណ្តាលឲ្យមានការបំផ្លិចបំផ្លាញ ដូចក្នុងករណីប្រទេសកម្ពុជានាពេលកន្លងមក និងក្នុងបណ្តាប្រទេសផ្សេងមួយចំនួនទៀតដែលមជ្ឈដ្ឋានបរទេសប៉ុនប៉ងឲ្យមានការផ្លាស់ប្តូរ។ បទពិសោធន៍ដ៏ជូរចត់នៃសង្គ្រាម និងរបបប្រល័យពូជសាសន៍ជិត ៣ ទសវត្សរ៍បានធ្វើឲ្យកម្ពុជាកំណត់យកអាទិភាពលើការថែរក្សាសន្តិភាព និងស្ថិរភាពដែលទទួលបានដោយលំបាក ព្រមទាំងការពង្រឹងនីតិរដ្ឋ ដើម្បីជានាថាការអភិវឌ្ឍដ៏ឆាប់រហ័សរបស់កម្ពុជានឹងបន្តដោយគ្មានការរាំងស្ទះ។

5. ការចោទប្រកាន់របស់សហរដ្ឋអាមេរិកដែលថា រាជរដ្ឋាភិបាលកម្ពុជាកំពុងចាត់វិធានការប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យគឺជាការនិយាយផ្ទុយនឹងទង្វើរបស់ខ្លួនឯង បើយើងពិនិត្យមើលគោលនយោបាយអាមេរិកកាលពីអតីតកាលដែលគាំទ្រការផ្លាស់ប្តូរមិនតាមបែបប្រជាធិបតេយ្យ និងបានបង្កឲ្យមានការបំផ្លិចបំផ្លាញមកលើប្រជាជន និងប្រទេសដ៏តូចមួយនេះ។ ភាពអយុត្តិធម៌ដ៏ជាក់ស្តែងបំផុត គឺសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តខ្លួនបានគាំទ្ររបបខ្មែរក្រហម ដែលគ្រប់គ្រងប្រទេសដោយគ្មានការគោរពសិទ្ធិមនុស្ស និងគ្មានលទ្ធិប្រជាធិបតេយ្យអ្វីទាំងអស់ ឲ្យកាន់កាប់អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ ហើយជំរុញឲ្យមានការអនុម័តសេចក្តីសម្រេចចិត្តរបស់អង្គការនេះដែលហាមឃាត់ការផ្តល់ជំនួយអភិវឌ្ឍន៍ដល់ប្រជាជាតិមួយដែលត្រូវបានបំផ្លិចបំផ្លាញដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិក។

6. ប្រតិកម្មរបស់សហរដ្ឋអាមេរិកចំពោះការវិវឌ្ឍនយោបាយនៅកម្ពុជានាពេលថ្មីៗនេះ ហាក់ដូចជាធ្វើឡើងមិនមែនក្រោមហេតុផលនៃគោលការណ៍លទ្ធិប្រជាធិបតេយ្យនោះទេ ប្រសិនបើពិចារណាលើការប្រព្រឹត្តរបស់សហរដ្ឋអាមេរិកចំពោះប្រទេសផ្សេងទៀតអំពីបញ្ហាប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។ ការវាយតម្លៃបែបនេះត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុងវេទិកាសួរសំណួរក្នុងអំឡុងពេលសន្និសីទកាសែតនៅក្រសួងការបរទេសអាមេរិកកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១៧ ផងដែរ។

7. ដោយមានគណបក្សនយោបាយជាច្រើនកំពុងលូតលាស់នៅកម្ពុជា លំហលទ្ធិប្រជាធិបតេយ្យ និងប្រព័ន្ធពហុបក្សនៅតែបន្តមាន។ កម្ពុជាប្តេជ្ញាចិត្តក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដែលអនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា និងរៀបចំការបោះឆ្នោតព្រឹទ្ធសភានៅថ្ងៃទី ២៥ ខែកុម្ភៈ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៨ ក្នុងបរិយាកាសសេរី យុត្តិធម៌ និងរបៀបរៀបរយ ដែលអាចទទួលយកបានសម្រាប់ម្ចាស់ឆ្នោតនៅកម្ពុជា។

ភ្នំពេញ ថ្ងៃទី៧ ខែធ្នូ ឆ្នាំ ២០១៧